**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

ថ្ងៃទី.19..ខែ.04..ឆ្នាំ ២០០៦...

# សូមគោរពជូន

## សម្តេច នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

*ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !*

**កម្មវត្ថុ** : សំណើគោរពស្នើសុំយោបល់ណែនាំដ៏ខ្ពង់ខ្ពស់ពី សម្តេច សម្រាប់ជាមូលដ្ឋានក្នុងការកែលំអឯកសារពិគ្រោះ ស្តីពី " ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ " ឱ្យកាន់តែមានសុក្រឹតភាព និងឥតលម្អៀង និងគោរពស្នើសុំប្រើប្រាស់ឯកសារនេះ ដោយផ្នែក ឬទាំងស្រុង នៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ ឬជាឯកសារជំនួយស្មារតី សម្រាប់សិស្សានុសិស្សទូទៅ ។

**យោង** : លិខិតចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៦ របស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន សម្តេច មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា : លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា គោរពស្នើសុំយោបល់ណែនាំដ៏ខ្ពង់ខ្ពស់ពី សម្តេច សម្រាប់ជាមូលដ្ឋានក្នុងការកែលំអឯកសារពិគ្រោះ ស្តីពី " ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ " ឱ្យកាន់តែមានសុក្រឹតភាព និងឥតលម្អៀង និងគោរពស្នើសុំប្រើប្រាស់ឯកសារនេះ ដោយផ្នែក ឬទាំងស្រុង ក្នុងកម្មវិធីសិក្សានៅថ្នាក់វិទ្យាល័យ ឬប្រើប្រាស់ជាឯកសារជំនួយសម្រាប់សិស្សានុសិស្សទូទៅ ។

ខ្ញុំបាទសូមគោរពបញ្ជាក់ជូន សម្តេច មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ផងដែរថា : ឯកសារនេះ គឺចងក្រង និងសិក្សាស្រាវជ្រាវដោយ លោក ឌី ខាំបូលី បច្ចុប្បន្នជាបុគ្គលិក នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងដឹកនាំកែសម្រួលខ្លឹមសារដោយលោក ឆាំង យុ។ ឯកសារនេះ មានចំនួន ៨៥ទំព័រ និងបានចែកចេញជា ១១ជំពូកគឺ : ជំពូកទី ១ : សេចក្តីសង្ខេប. ជំពូកទិ ២ : តើខ្មែរក្រហមជាអ្នកណា ? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា ?. ជំពូកទី ៣ : ការឡើងកាន់អំណាចរបស់ខ្មែរក្រហម. ជំពូកទី ៤ : ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ. ជំពូកទី ៥ : ភូមិសាស្ត្ររដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ. ជំពូកទី ៦ : គម្រោង ផែនការបួនឆ្នាំ ( ១៩៧៧-១៩៨០ ), ជំពូកទី ៧ : ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ. ជំពូកទី ៨ : ប្រព័ន្ធសន្តិសុខ. ជំពូកទី ៩ : មន្ទីរ ស-២១ ( គុកទួលស្លែង ), ជំពូកទ ១០ : ទំនាក់ទំនងការបរទេស. ជំពូកទី ១១ : ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខ្ញុំបាទបានពិនិត្យឃើញថា : នៅក្នុងឯកសារនេះ គឺបានឆ្លុះបញ្ចាំង អំពីសកម្មភាពឥតលម្អៀង នៃតថភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងសំខាន់ សម្រាប់ប្រជាជនកម្ពុជា និងពិភពលោកពិសេសគឺ សិស្សានុសិស្ស ដែលនឹងធ្វើឱ្យពួកគេមើលឃើញយ៉ាងពិតប្រាកដ មិនអាចបំភ្លេចបាននូវរបបដ៏ឃោរឃៅព្រៃផ្សៃបំផុតនេះ ប៉ុន្តែចំណុចសំខាន់ដែលគួរឱ្យចាប់អារម្មណ៍ និងត្រូវកែសម្រួលនោះគឺ :

១-<u>ក្នុងអារម្ភកថា ទំព័រទី ៨ ផ្នែកខាងដើមនៃឯកសារ បានសរសេរថា</u> : " *ចាប់តាំងពីការដួលរលំ នៃអាណាចក្រអង្គរ រហូតមកដល់បច្ចុប្បន្ន ប្រជាជនកម្ពុជាបានជួបប្រទះនូវសង្គ្រាមឈ្លានពាន និងការដណ្តើមអំណាចគ្នារវាងមេដឹកនាំរបស់ខ្លួន* "។ .......

នៅក្នុងផ្នែកនេះ គួរកែសម្រួលជាក់ថា " ចាប់តាំងពីការដួលរលំ នៃអាណាចក្រអង្គរ រហូតមកដល់ថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ ប្រជាជនកម្ពុជាដែលនៅសេសសល់ពី ការកាប់សម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានរស់រានមានជីវិតសាជាថ្មី។ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ( សន្ធិសញ្ញាសន្តិភាពកម្ពុជា នៅទីក្រុងប៉ារីស ) " បន្ទាប់មកអង្គការសហប្រជាជាតិ បានរៀបចំការបោះឆ្នោតសាកលនៅកម្ពុជា នាថ្ងៃទី ២៥-២៦-២៧ ខែ ឧសភា ឆ្នាំ ១៩៩៣ និងជាបន្តបន្ទាប់មកទៀត នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ និងថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ កម្ពុជាបានរៀបចំការបោះឆ្នោតសាកលដោយខ្លួនឯង។

ដូច្នេះក្នុងចំណុចនេះ គឺត្រូវបញ្ជាក់ឱ្យបានច្បាស់ថា គណបក្សប្រជាជនកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេច ពុំដែលដណ្តើមអំណាចពីអ្នកណាឡើយ ពោលគឺ អំណាចដែលគណបក្សប្រជាជនកម្ពុជា ក្តាប់ [illegible] មកដល់បច្ចុប្បន្ននេះ គឺបានដោយសារការគាំទ្រយ៉ាងសកម្ម និងអស្ចារ្យពីប្រជាជនកម្ពុជា។

<u>២-ក្នុងជំពូកទី ១ ( សេចក្តីសង្ខេប ) ទំព័រទី ១០ បានសរសេរថា</u> : " *នៅខែ ធ្នូ ឆ្នាំ ១៩៧៨ កងទ័ពវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ( រណសិរ្សដែលដឹកនាំដោយកងទ័ព ដែលរត់ចេញពីជួរខ្មែរក្រហម ) បានធ្វើការវាយសម្រុកចូលប្រទេសកម្ពុជា ហើយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩*។ .......

ក្នុងផ្នែកនេះ គួរកែសម្រួលជាក់ថា : " *នៅខែ ធ្នូ ឆ្នាំ ១៩៧៨ កងទ័ពវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចូលរំដោះប្រជាជនកម្ពុជា ហើយបានដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩*។ ......." ដោយឡែកឃ្លាដែលថា : ( <u>*រណសិរ្សដែលដឹកនាំដោយកងទ័ព ដែលរត់ចេញពីជួរខ្មែរក្រហម*</u> ) ត្រូវលុបចេញទាំងស្រុង ពីព្រោះថា គណបក្សប្រជាជនកម្ពុជា មិនមែនកើតចេញពីកងទ័ពខ្មែរក្រហមនោះទេ ប៉ុន្តែគឺជាកម្លាំងមហាជន ដែលងើបឡើងតស៊ូប្រឆាំងទៅនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត រហូតបង្កើតបានរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៧៨។

<u>*បញ្ជាក់*</u> : ចំណុចដែលគួរកែសម្រួលទាំងពីរខាងលើនេះ ខ្ញុំបាទបានពិគ្រោះយោបល់ជាមួយលោក ឆាំង យុ រួចហើយ។ គាត់បានយល់ស្របជាមួយ ខ្ញុំបាទ ដើម្បីកែសម្រួលឃ្លានេះ បន្ទាប់ពីទទួលបាននូវការណែនាំដ៏ខ្ពង់ខ្ពស់ពី សម្តេច " នៅក្នុងឯកសារស្តីពី " ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ " នេះដែរ ក្រៅពីឯកសារពិគ្រោះនានា ក៏មានសៀវភៅរបស់ សម្តេច " ១០ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩ " និង " ១៣ទសវត្សនៃ ដំណើរកម្ពុជា " ផងដែរ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើនេះ គួរពុំគួរ សូម សម្តេច មេត្តាពិនិត្យ និងមេត្តាផ្តល់នូវមតិណែនាំដ៏ខ្ពង់ខ្ពស់បំផុត។

សូម សម្តេច មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុត អំពីខ្ញុំបាទ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

[illegible]

26. 7. 2006

[signature]

ស៊ាន ប៊ុរ៉ាត

[signature]